**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ០៦ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពីការបង្កើតទិវាវប្បធម៌ជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

- យោងអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតទិវាវប្បធម៌ជាតិ

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

## សម្រេច

**មាត្រា ១** .-កំណត់យកថ្ងៃ០៣ ខែមីនា រៀងរាល់ឆ្នាំជាថ្ងៃបើក "**ទិវាវប្បធម៌** "របស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈធ្វើជា "**ទិវាវប្បធម៌ជាតិ** " នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** .-ក្នុងលក្ខណៈត្រៀមប្រារព្ធ "**ទិវាវប្បធម៌ជាតិ** " ០៣ មីនា គ្រប់ក្រសួងស្ថាប័នរដ្ឋ អាជ្ញាធរគ្រប់ខេត្តក្រុង គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុនឯកជន សមាគមនានាត្រូវបំផុសអប់រំមន្ត្រីរាជការ នគរបាល កងទ័ពគ្រប់ប្រភេទ សិស្ស និស្សិត ព្រះសង្ឃ ប្រជាពលរដ្ឋគ្រប់ស្រទាប់អោយយល់ដឹងអំពីនយោបាយវប្បធម៌ជាតិ អត្តសញ្ញាណជាតិ ស្មារតីការពារវប្បធម៌សិល្បៈ បេតិកភណ្ឌវប្បធម៌ជាតិ ទំនៀមទំលាប់ប្រពៃណីដ៏ល្អប្រពៃរបស់ជាតិ និងស្មារតីគោរពច្បាប់ និងបទបញ្ញត្តិនានា ស្តីពីការគ្រប់គ្រង និងការពារសម្បត្តិវប្បធម៌ជាតិ និងបរិស្ថានវប្បធម៌ជាតិ ។

**មាត្រា ៣** .- បង្កើតគណៈកម្មការអន្តរក្រសួងមួយសម្រាប់រៀបចំប្រារព្ធ " **និទាឃបុប្ផធម៌ជាតិ** "០៣ មីនារៀងរាល់ឆ្នាំ ចាប់តាំងពីឆ្នាំ ២០០៦ នេះតទៅ ដើម្បីបង្ហាញពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្នុងការស្តារវប្បធម៌ជាតិ និងលើកកំពស់ការយល់ដឹងអំពីអត្ថប្រយោជន៍នៃវិស័យវប្បធម៌ និងវិចិត្រសិល្បៈ សំដៅរួមចំណែកស្តារ និងអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។

សមាសភាពនៃគណៈកម្មការនេះមាន :

| | |
|---|---|
| ១-រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ជាប្រធាន |
| ២-រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣-អនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ -អន្តរជាតិ | ជាអនុប្រធាន |
| ៤-រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាអនុប្រធាន |
| ៥-រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា | ជាសមាជិក |
| ៦-រដ្ឋលេខាធិការក្រសួងព័ត៌មាន | ជាសមាជិក |
| ៧-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៨- រដ្ឋលេខាធិការក្រសួងការពារជាតិ | ជាសមាជិក |
| ៩- រដ្ឋលេខាធិការក្រសួងទេសចរណ៍ | ជាសមាជិក |
| ១០-រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ១១-រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ១២-រដ្ឋលេខាធិការក្រសួងធម្មការ និងកិច្ចការសាសនា | ជាសមាជិក |
| ១៣-រដ្ឋលេខាធិការក្រសួងកិច្ចការនារី | ជាសមាជិក |
| ១៤-អភិបាលរងរាជធានីភ្នំពេញ និងអភិបាលរងខេត្ត-ក្រុង ទូទាំងប្រទេស | ជាសមាជិក |

**មាត្រា ៤** .-គណៈកម្មការនេះមានភារកិច្ច :

-ធ្វើសារាចរណែនាំ ស្តីពីការរៀបចំប្រារព្ធពិធី "**និទាឃបុប្ផធម៌ជាតិ**" ០៣ មីនា

-រៀបចំប្រធានបទ ខ្លឹមសារ រូបភាពបំរើអោយ " **និទាឃបុប្ផធម៌ជាតិ** "ក្នុងឆ្នាំនីមួយៗ

-បង្កើតអនុគណៈកម្មការមួយចំនួន បើមានការចាំបាច់

-បំផុស និងអំពាវនាវគ្រប់មជ្ឈដ្ឋាន និងសប្បុរសជនដើម្បីជួយឧបត្ថម្ភគាំទ្រ " **និទាឃបុប្ផធម៌ជាតិ** " ។

**មាត្រា ៥** .-គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ៦** .-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជួយសម្របសម្រួលថវិកាជូនគណៈកម្មការនេះតាមតម្រូវការ ជាក់ស្តែង ។

**មាត្រា ៧** .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨** .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ - អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត -ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧-៨
- ឯកសារ -កាលប្បវត្តិ